មជ្ឈមណ្ឌលឯកសារកម្ពុជា

**គម្រោងស្តីពីការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ**

**ការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)**

**សិក្ខាសាលាជាមួយគ្រូបង្រៀន-ក្រុមការងារស្តីពីការចងក្រងឯកសារប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ**

**ប្រាសាទព្រះវិហារ ថ្ងៃទី ២៤-២៦ ខែធ្នូ ឆ្នាំ២០១០**

# ប្រកាសព័ត៌មាន

ក្នុងថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១០ មជ្ឈមណ្ឌលឯកសារកម្ពុជាសហការជាមួយក្រសួងអប់រំ យុវជន និងកីឡានឹងរៀបចំកិច្ចប្រជុំការងារជាមួយលោកគ្រូអ្នកគ្រូប្រចាំឆ្នាំលើកទីពីររបស់ខ្លួននៅខេត្តព្រះវិហារ ក្នុងបំណងបង្កើតឡើងនូវក្រុមការងារមួយ ដើម្បីចងក្រងឯកសារប្រវត្តិសាស្ត្រកម្ពុជាតាមរយៈដំណើរការស្វែងរកការពិតនិងផ្សះផ្សា ។ អ្នកចូលរួមនៅក្នុងសិក្ខាសាលានេះ រួមមានគ្រូបង្គោលថ្នាក់ជាតិចំនួន២៣រូបនិងគ្រូបង្គោលថ្នាក់ខេត្តចំនួន១៨០រូប ។ សិក្ខាសាលានេះ នឹងផ្តោតការពិភាក្សាទៅលើប្រធានបទសំខាន់ៗចំនួន៤គឺ ៖

***ការបង្កើតក្រុមការងារមួយសម្រាប់ចងក្រងឯកសារប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ*** ៖ មជ្ឈមណ្ឌលឯកសារកម្ពុជាជឿជាក់ថា ដំណើរការនៃការស្វែងរកការពិត និងផ្សះផ្សាមួយ ដែលស្របទៅនឹងបរិបទសង្គម និងវប្បធម៌របស់កម្ពុជាគួរតែត្រូវបានបង្កើតឡើងដើម្បីជំរុញដល់ការទប់ស្កាត់អំពើប្រល័យពូជសាសន៍ និងការផ្សះផ្សាជាតិ និងដើម្បីចងក្រងឯកសារទាក់ទងទៅនឹងអំពើឧក្រិដ្ឋកម្មធ្ងន់ធ្ងរដែលត្រូវបានប្រព្រឹត្តឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។

***ការអភិវឌ្ឍន៍ជំនាញ*** ៖ សិក្ខាសាលានេះនឹងផ្តោតទៅលើការពង្រឹងសមត្ថភាពរបស់គ្រូបង្គោលថ្នាក់ជាតិនិងគ្រូបង្គោលថ្នាក់ខេត្តដែលជាគ្រូឧទ្ទេសនៅក្នុងវគ្គបណ្តុះបណ្តាលគ្រូមូលដ្ឋានលើកក្រោយៗទៀត ។ នៅក្នុងឆ្នាំ២០១១ និងឆ្នាំបន្តបន្ទាប់ទៀត មជ្ឈមណ្ឌលឯកសារកម្ពុជា និង ក្រសួងអប់រំ យុវជន និងកីឡានឹងបន្តផ្តល់ការបណ្តុះបណ្តាលដល់គ្រូមុខវិជ្ជាប្រវត្តិវិទ្យា ដែលនៅសេសសល់ និងលោកគ្រូអ្នកគ្រូបង្រៀនមុខវិជ្ជាភាសាខ្មែរ និងសីលធម៌ពលរដ្ឋ ។

***ប្រសិទ្ធិភាពនៃការបង្រៀន*** ៖ សិក្ខាសាលានេះនឹងពិភាក្សាថាតើគ្រូបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនៅក្នុងថ្នាក់រៀនដោយរបៀបណា ។ សំណួរចម្បងៗមួយចំនួននឹងត្រូវលើកយកមកពិភាក្សា ។ តើគ្រូអាចយកចំណេះដឹង ជំនាញ និងវិធីសាស្ត្រដែលខ្លួនទទួលបានពីវគ្គបណ្តុះបណ្តាលទៅអនុវត្តនៅក្នុងថ្នាក់រៀនបានដែរឬទេ? តើគ្រូអាចបង្រៀនមេរៀននៅក្នុងសៀវភៅប្រវត្តិសាស្ត្រកម្ពុជា

Documentation Center of Cambodia
Searching for the Truth: Memory & Justice ស្វែងរកការពិត ដើម្បីការចងចាំនិងយុត្តិធម៌
66 Preah Sihanouk Blvd. ◆ P.O.Box 1110 ◆ Phnom Penh ◆ Cambodia
t (855-23) 211-875 ◆ f (855-23) 210-358 ◆ dccam@online.com.kh ◆ www.dccam.org

ប្រជាធិបតេយ្យនៅក្នុងថ្នាក់រៀនបានចំនួនប៉ុន្មាន? តើគ្រូអាចអនុវត្តការបង្រៀនប្រកបដោយប្រសិទ្ធិ-ភាពនៅក្នុងបរិបទនៃបរិស្ថានក្នុងថ្នាក់រៀនរបស់ខ្លួនបានដែរឬទេ? តើបញ្ហាប្រឈមអ្វីខ្លះ ដែលគ្រូបានជួបប្រទះនៅក្នុងកំឡុងពេលនៃការបង្រៀននៅក្នុងការអនុវត្តនូវវិធីសាស្ត្រថ្មី និងសម្ភារឧបទ្ទេស ដែលមជ្ឈមណ្ឌលឯកសារកម្ពុជាបានផ្តល់ឲ្យ?

**ការចងក្រងរឿងរ៉ាវរបស់អ្នកដែលនៅរស់រានមានជីវិត** ៖ នៅក្នុងតួនាទីរបស់ខ្លួនជាអ្នកស្វែងរកការពិតគ្រូបង្គោលទាំងអស់នឹងមានតួនាទីបន្ថែមទៀត មិនមែនមានតួនាទីត្រឹមតែអប់រំសិស្សអំពីប្រវត្តិ-សាស្ត្រខ្មែរក្រហមប៉ុណ្ណោះទេ ថែមទាំងមានតួនាទីលើកទឹកចិត្តសិស្សទាំងអស់ឲ្យធ្វើការចងក្រងនូវរឿងរ៉ាវរបស់ឪពុកម្តាយ ជីដូនជីតា សាច់ញាតិ និងអ្នកជិតខាង ដើម្បីថែរក្សាការចងចាំពីអំពើហិង្សានៅក្នុងអតីតកាល ដែលជាផ្នែកមួយនៃដំណើរការស្វែងរកការពិត និងផ្សះផ្សា ។

អត្ថបទពិភាក្សាប្រាំពីរនឹងធ្វើការពិភាក្សានៅក្នុងសិក្ខាសាលានេះ ៖

**អត្ថបទពិភាក្សាទី១** ៖ យុត្តិធម៌បន្ទាប់បន្សំ ដោយ ឆាំង យុ ។

**អត្ថបទពិភាក្សាទី២** ៖ ការអត់ឱនទោស ៖ តើការអត់ឱនអាចទៅរួចដែរឬទេ ហើយតើអាចបង្រៀនឲ្យចេះអត់ឱនបានដែរឬទេ? ដោយ អេង កុកថាយ ។

**អត្ថបទពិភាក្សាទី៣** ៖ ទស្សនៈសំខាន់ៗស្តីពីការអភិវឌ្ឍន៍ជំនាញ ដោយ គ្រីស ឌេវីង និង ស៊ីរ៉ា សាវីណា ។

**អត្ថបទពិភាក្សាទី៤** ៖ ប្រសិទ្ធិភាពនៃការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ដោយ ជា ផល្លា

**អត្ថបទពិភាក្សាទី៥** ៖ ទ្រឹស្តី និង ការអនុវត្តប្រវត្តិសាស្ត្រតាមរយៈការសួរនាំ ។

**អត្ថបទពិភាក្សាទី៦** ៖ បទពិសោធន៍ពីការធ្វើការជាមួយសហគមន៍ចាម ដោយ សូ ហ្វារីណា ។

**អត្ថបទពិភាក្សាទី៧** ៖ ហេតុអ្វីគ្រូវធ្វើការគ្រប់គ្រងគុណភាពការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ។

នៅក្នុងពេលដែលមជ្ឈមណ្ឌលឯកសារកម្ពុជាធ្វើការជាមួយជនរងគ្រោះដោយសាររបបខ្មែរក្រហម យើងបានឮប្រជាជនរៀបរាប់ពីឱកាសដ៏កម្រនៅពេលដែលឡានរបស់រដ្ឋាភិបាលលោកខាងលិចនានាស្រាប់តែមកដឹកយកជនភៀសខ្លួនដើម្បីទៅរស់នៅឯប្រទេសរបស់ពួកគេ ។ នេះជារឿងរ៉ាវពិត ដែលប្រហែលជាត្រូវនឹងសាច់រឿងពួកគេ តើមានអ្វីកើតឡើងបន្តទៀត ។ នៅខែមិថុនា ឆ្នាំ១៩៧៩ ប្រទេសថៃបានប្រកាសថា ជនភៀសខ្លួនកម្ពុជាយ៉ាងច្រើនត្រូវបានបណ្តេញចេញពីទឹកដីថៃ ។ ជន

ភៀសខ្លួន១២០០នាក់ត្រូវបានជ្រើសរើសឲ្យទៅរស់នៅសហរដ្ឋអាមេរិក បារាំង និងអូស្ត្រាលី ។ ទោះជាយ៉ាងណាក្តី ជនភៀសខ្លួនដែលនៅសល់ត្រូវបានបញ្ជូនចូលមកប្រទេសកម្ពុជាវិញ ។ អ្នកទាំងអស់នោះត្រូវបានបញ្ជូនមកតាមព្រះវិហារ ។ ទោះជាចំណោតភ្នំនៃខេត្តព្រះវិហារកម្ពុជានិងខេត្តស៊ីសាកេតថៃ មានលក្ខណៈចោតយ៉ាងខ្លាំងនៅពេលដែលពួកគេឆ្ពោះមកខាងកម្ពុជា ។ នៅតាមផ្លូវមួយចំនួន ដែលអាចឆ្លងកាត់បានពីខាងថៃនោះត្រូវបានបង្កប់ទៅដោយគ្រាប់មីនដោយខ្មែរក្រហមនៅសម័យនោះដើម្បីការពារកុំឲ្យប្រជាជនខ្មែររត់ទៅប្រទេសថៃ ។ តាមព័ត៏មានបានឲ្យដឹងថា ប្រជាជនខ្មែរជាង៣០០០នាក់ត្រូវស្លាប់ដោយសារការបញ្ជូនត្រឡប់មកកម្ពុជាវិញនេះ និងប្រជាជនជាង៧០០០នាក់ ដែលគ្មានការទទួលខុសត្រូវយកចិត្តទុកដាក់ ។ នៅតែមិនទាន់យល់ច្បាស់ថា ហេតុអ្វីបានជាប្រជាជនទាំងនោះត្រូវគេបញ្ជូនមកតាមព្រះវិហារ ហេតុអ្វីបានជាមិនបញ្ជូនមកតាមច្រកផ្សេងដែលមានសុវត្ថិភាពជាងច្រកនេះ ។ រហូតដល់ឆ្នាំ១៩៧៩ មានចលនាបញ្ជូនប្រជាជនឲ្យត្រឡប់មកស្រុកខ្មែរវិញជាច្រើន តាមផ្លូវដដែលរួមទាំង៨៥០នាក់ត្រូវបានគេបញ្ជូនចេញពីខេត្តអរញ្ញប្រថេត ។ មានសេចក្តីរាយការណ៍ឲ្យដឹងថា មានទាហានថៃបានបាញ់ពីក្រោយ នៅពេលដែលពួកគេបង្ខំប្រជាជនខ្មែរដើរឆ្លងកាត់ចំការមីន ។

ព្រះវិហារជាខេត្តដែលឋិតនៅភាគពាយ័ព្យនៃប្រទេសកម្ពុជា ។ ខេត្តនេះត្រូវបានដាក់ឈ្មោះតាមប្រាសាទព្រះវិហារដែលឋិតនៅជាប់ព្រំប្រទល់រវាងប្រទេសកម្ពុជានិងថៃ ។ ប្រាសាទនេះត្រូវបានកសាងឡើងនៅដើមសតវត្សទី៩ឧទ្ទិសទៅអទិទេពព្រាហ្មណ៍សាសនា ។ នៅសម័យនោះអាណាចក្រខ្មែរលាតសន្ធឹងយ៉ាងហោចណាស់ដល់ទន្លេចៅផាយ៉ា ។ រាប់ពាន់ឆ្នាំមកហើយ ប្រាសាទនេះក្លាយជាកន្លែងគោរពបូជាទាំងអ្នកប្រណិបត្តពុទ្ធ សាសនា និងព្រាហ្មណ៍សាសនា ។ ប្រាសាទព្រះវិហារជាទីតាំងជម្លោះរវាងប្រទេសថៃនិងកម្ពុជាអស់រយៈកាលជាងមួយរយឆ្នាំមកហើយ ។ យោងតាមផែនទីដែលគូរពីការគ្រប់គ្រងរបស់បារាំងនៅអាស៊ីអាគ្នេយ៍នៅដើមទសវត្សទី៩០ និង ការសម្រេចក្តីរបស់តុលាការអន្តរជាតិ(ICJ) បានបង្ហាញថា ប្រាសាទនេះឋិតនៅក្នុងដែនដីកម្ពុជា ហើយកម្ពុជាគឺជាម្ចាស់កម្មសិទ្ធិនិងមានអធិបតេយ្យភាពលើប្រាសាទនេះ ។ ការដើមឡើង ការធ្វើដំណើរឡើងប្រាសាទពីខាងកម្ពុជាមានការលំបាក ។ ចំណែកខាងថៃគឺជាជម្រាលភ្នំចុះប្រហែលជាជាង១០០ម៉ែត្ររបូតដល់ព្រំដែនកម្ពុជា ។ ជម្រាលភ្នំនេះបង្កើតឲ្យមានព្រំដែនជាលក្ខណៈធម្មជាតិមួយរវាងប្រទេសទាំងពីរនេះ ។ ទោះជាយ៉ាងណាក្តី ផ្លូវឆ្ពោះទៅកាន់ប្រាសាទមានលក្ខណៈប្រសើរឡើង ដោយសារមានការកសាងផ្លូវពីខេត្តព្រះវិហារទៅតំបន់ប្រាសាទនិងពីជើងភ្នំឡើងទៅកំពូលភ្នំ ។ បន្ទាប់ពីការប្រកាសសាលក្រមរបស់តុលាការអន្តរជាតិខាងភាគីថៃមិនបានធ្វើការប្តឹងសារទុក្ខនិងធ្វើការបដិសេធទេ ។ ក្រៅពីមានសិទ្ធិគ្រប់គ្រងលើប្រាសាទ សេចក្តី

នៅក្នុងសាលក្រមបានបញ្ជាក់ថា ភាគីខាងកម្ពុជាអាចទាមទាររាល់វត្ថុសិល្បៈនានា ដែលត្រូវបានយកចេញ ។ នេះជាជោគជ័យមួយ ដែលប្រទេសកម្ពុជាទទួលបាន ហើយកត្តិយសដ៏ធំធេងនេះ ត្រូវថ្វាយជូនព្រះមហាក្សត្រក្មេងវ័យ នរោត្តម សីហនុ ។ ទោះជាយ៉ាងនេះ ក្តីប៉ុន្មានឆ្នាំមកនេះចាប់តាំងពីការប្រកាសសាលក្រមរបស់តុលាការអន្តរជាតិនោះមកកម្ពុជាធ្លាក់ទៅក្នុងជម្លោះដ៏ហឹង្សានិងអូសបន្លាយចាប់តាំងពីឆ្នាំ១៩៧០ដល់១៩៩៨ ។ ប្រាសាទព្រះវិហារបានក្លាយជាទីកន្លែងលាក់កំបាំង និងជាទីតាំងកាន់កាប់មួយរបស់ខ្មែរក្រហម ។ ប្រាសាទព្រះវិហារគឺជាទីតាំងមួយក្នុងចំណោមទីតាំងចុងក្រោយនានាដែលបានយកមកពីខ្មែរក្រហម ។

រហូតដល់ឆ្នាំ២០០៨នេះភ្ញៀវទេសចរណ៍ត្រូវបានអនុញ្ញាតឲ្យចូលទស្សនាប្រាសាទតាមខាងប្រទេសថៃមានផ្សារមួយនៅតាមព្រំដែនត្រូវបានគេបើកនៅជិតប្រាសាទនៅជាប់ព្រំដែនកម្ពុជា ថៃ ។ ព្រះវិហារគឺជាប្រាសាទដែលពោរពេញទៅដោយប្រវត្តិសាស្ត្រ ។ ប្រាសាទនេះមានផ្នែកមួយចំនួននៃអារ្យធម៌របស់កម្ពុជាដែលបានបាត់បង់ ។ វាត្រូវបានប្រជាជនខ្មែរចាត់ទុកថា ជានិមិត្តរូបដ៏ជោគជ័យមួយទៅលើថៃដែលត្រូវបានគិតថាជាអ្នកកេងប្រវញ្ច ។ ជម្លោះនេះមិនទាន់បានដោះស្រាយនៅឡើយ ។ ហេតុនេះហើយទីតាំងខេត្តព្រះវិហារជាទីតាំងដែលសមស្របមួយសម្រាប់មជ្ឈមណ្ឌលឯកសារកម្ពុជារៀបចំសិក្ខាសាលាជាមួយគ្រូស្តីពីការចងក្រងឯកសារប្រវត្តិសាស្ត្រ ។

សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនង ៖

អេង កុកថាយ តាមរយៈអ៊ីមែល truthkokthay@dccam.org
ទូរស័ព្ទ ៖ ០១២ ៩៥ ៥៨ ៥៨ និង
ហ៊ុយ សម្ផស្ស តាមរយៈអ៊ីមែល truthsamphoas@dccam.org
ទូរស័ព្ទ ៖ ០១២ ៩៦ ៥២ ៨៥